# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម

សំណុំរឿង០០២ ■ របាយការណ៍លេខ ៤៩ ■ សវនាការលើកស្តុតាង ■ សប្តាហ៍ទី ៤៤ ■ ១៤ មករា ២០១៣




Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*យើងបានទទួលដំណឹងថា កូនក្តីរបស់ខ្ញុំត្រូវបាននាំទៅមន្ទីរពេទ្យជាបន្ទាន់*
*ដោយហេតុថាគាត់បានដួល...*

- មេធាវីអន្តរជាតិការពារជនជាប់ចោទ នួន ជា លោក វិចទ័រ កូប៉េ

## I. ទិដ្ឋភាពទូទៅ

នៅថ្ងៃអាទិត្យទី ១៣ មករា ជនជាប់ចោទ នួន ជា ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យដោយសាររោគរលាកទងសួតធ្ងន់ធ្ងរ។ ដូច្នេះ អង្គជំនុំជម្រះតុលាការដំបូង បានបើកសវនាការដោយសង្ខេបនៅថ្ងៃទី ១៤ មករា មុនពេលសម្រាក ដើម្បីផ្តល់ឱកាសឲក្រុមការពារក្តី លោក នួន ជា ពិភាក្សាជាមួយកូនក្តីរបស់ខ្លួន ថាតើគាត់បោះបង់សិទ្ធិមានវត្តមានក្នុងតុលាការឬយ៉ាងណានោះទេ។ ក្រោយមកក្នុងសប្តាហ៍នេះ លោក ខៀវ សំផន ក៏ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យផងដែរ។ ដោយពិចារណាទៅលើសិទ្ធិមានវត្តមានក្នុងពេលធ្វើសវនាការរបស់ជនជាប់ចោទ និង ស្ថានភាពសុខភាពយ៉ាប់យឺនរបស់ពួកគាត់ អង្គជំនុំជម្រះ បានសម្របសម្រួលលើបញ្ហារៀបចំកិច្ចដំណើរការសវនាការឡើងវិញនៅក្នុងសប្តាហ៍បន្តបន្ទាប់ខាងមុខ។

## II. បញ្ហាផ្នែកច្បាប់ និងនីតិវិធី

ដោយសារតែ លោក នួន ជា និង លោក ខៀវ សំផន ត្រូវបានព្យាបាលនៅមន្ទីរពេទ្យក្នុងអំឡុងពេលសប្តាហ៍នេះ ហើយ លោក អៀង សារី បានត្រឹមតែតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់តាមដានជាន់ក្រោម ដោយសារបញ្ហាសុខភាព បញ្ហាទាំងនេះ បានបណ្តាលឲសិទ្ធិមានវត្តមានក្នុងកិច្ចដំណើរការនីតិវិធីនិងសិទ្ធចូលរួមការពារក្តីរបស់ជនជាប់ចោទក្លាយជាបញ្ហាចម្បង ដែលអង្គជំនុំជម្រះតុលាការដំបូងត្រូវដោះស្រាយក្នុងសប្តាហ៍នេះ។

## ក. សិទ្ធិក្នុងការមានវត្តមានរបស់ នួន ជា និង ខៀវ សំផន

នៅដើមវគ្គសវនាការថ្ងៃច័ន្ទ ក្រឡាបញ្ជីបានជូនដំណឹងដល់អង្គជំនុំជម្រះនិងភាគីថា ជនជាប់ចោទ នួន ជា បានអវត្តមាន។ យោងតាមរបាយការណ៍វិជ្ជសាស្ត្របឋម លោក នួន ជា បានកំពុងឈឺចាប់ពីជម្ងឺរលាក ទងសួតជាទម្ងន់ ហើយត្រូវបានបញ្ជូនទៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅល្ងាចថ្ងៃអាទិត្យម៉ោង ៥:១៥។ ជនជាប់ចោទ ប្រហែលជាត្រូវស្នាក់នៅមន្ទីរពេទ្យពី៤ទៅ៧ថ្ងៃ។ មេធាវីអន្តរជាតិឲ លោក នួន ជា លោក វ៉ិចទ័រ កូប៉េ បាននិយាយថា ក្រុមការពារក្តីរបស់គាត់ ត្រូវបានផ្តល់ព័ត៌មាននៅល្ងាចថ្ងៃអាទិត្យថា លោក នួន ជា បានដួលអស់ជំហរនៅក្នុងមន្ទីរឃុំឃាំង។ ដោយសារតែឧបទ្ទវហេតុនេះបានកើតឡើងនាពេលល្ងាច ពួកគាត់ មិនអាចពិភាក្សាជាមួយកូនក្តីរបស់ខ្លួនពីការបោះបង់សិទ្ធិមានវត្តមានរបស់គាត់បានឡើយ។ ដូច្នេះ លោក កូប៉េ បានស្នើឲសម្រាកកិច្ចដំណើរការនីតិវិធី ដើម្បីឲគាត់មានឱកាសប្រឹក្សាជាមួយកូនក្តីរបស់ខ្លួន។ មិនមានភាគីណាមួយជំទាស់នឹងសំណើនេះទេ។ ក្រោយពេលប្រឹក្សាសង្ខេប អង្គជំនុំជម្រះ តាមរយៈចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ បានយល់ព្រមនឹងសំណើរ ហើយប្រកាសសម្រាកកិច្ចដំណើរការនីតិវិធី។ ចៅក្រម ខាតវ៉ាយថ៍ ក៏បាននិយាយផងដែរថា អង្គជំនុំជម្រះនឹងជូនដំណឹងដល់ភាគី ប្រសិនបើសវនាការនឹងត្រូវបើកបន្តឡើងវិញក្នុងសប្តាហ៍នោះ។

នៅថ្ងៃទី ១៦ មករា អង្គជំនុំជម្រះបានចេញអនុស្សរណៈមួយ ដើម្បីបញ្ជាក់ថា អង្គជំនុំជម្រះបានទទួលដំណឹងនៅថ្ងៃដដែលថា លោក **ខៀវ សំផន** *"ត្រូវបានបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតផងដែរ។"*[1] ជាកិច្ចបន្ថែម អនុស្សរណៈនេះ បានថ្លែងថា លោក **នួន ជា** បានបញ្ជាក់ថា គាត់មិនលះបង់សិទ្ធិក្នុងការមានវត្តមានសម្រាប់កិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿងលេខ០០២/០១ នេះឡើយ។[2] ដូច្នេះអង្គជំនុំជម្រះ *"សម្រេចផ្អាកការកោះហៅសាក្សី អ្នកជំនាញ និង ដើមបណ្តឹងរដ្ឋប្បវេណី រហូតដល់ជនជាប់ចោទមានលទ្ធភាពអាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនការដោយផ្ទាល់ ឬតាមរយៈឧបករណ៍សោតទស្សន៍ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ អនុលោមតាមវិធាន ៨១(៥) ឬក៏ជ្រើសរើសការលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅបន្ទប់សវនាការ។"*[3]

ទោះបីជាមានបត់បែនបែបនេះក៏ដោយ អង្គជំនុំជម្រះ បាននិយាយថា អង្គជំនុំជម្រះនឹង *"ព្យាយាមបន្តកិច្ចដំណើរការនីតិវិធី ជាមួយការពិចារណាអំពីលទ្ធភាពនៃការធ្វើសវនាការដេញដោលលើឯកសារ និងការបង្ហាញឯកសារដែលពាក់ព័ន្ធបំផុតសម្រាប់ការបញ្ជាក់ការពិតក្នុងសំណុំរឿង ០០២/០១។"* ចុងក្រោយតុលាការបានស្នើឲក្រុមការពារជនជាប់ចោទ **នួន ជា** និង **ខៀង សំផន** បញ្ជាក់ថាតើកូនក្តីរបស់ខ្លួននឹងមានបំណងលះបង់សិទ្ធិមានវត្តមានសម្រាប់សវនាការលើឯកសារនេះដែរឬទេ។[4] សវនាការលើឯកសារនេះត្រូវបានធ្វើកាលបរិច្ឆេទមុនពេលកំណត់នៅថ្ងៃទី ១៨-២១ កុម្ភៈ ២០១៣ (E236/4)។[5]

យ៉ាងណាមិញ អង្គជំនុំជម្រះបានណែនាំថា អង្គជំនុំជម្រះនឹងព្យាយាមបើកសវនាការទាំងនេះមុនពេលកំណត់ ប្រសិនបើវានៅតែមិនអាចទៅរួចក្នុងការស្តាប់សវនាការលើភស្តុតាងក្នុងអំឡុងពេលសប្តាហ៍ចាប់ផ្តើមពីថ្ងៃទី ២១ មករា ២០១៣។

## ខ. សិទ្ធិចូលរួមការពារក្តីដោយមានប្រសិទ្ធិភាពរបស់ អៀង សារី

ក្រៅពីបញ្ហាសុខភាពថ្មីៗនេះរបស់លោក **នួន ជា** និង លោក **ខៀវ សំផន** ក្រុមការពារក្តីឲ លោក **អៀង សារី** បានកំពុងលើកឡើងពីសំណួរជុំវិញបញ្ហាសម្បទារបស់ **អៀង សារី** ដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយមានប្រសិទ្ធិភាព និងផ្តល់ជំនួយមតិយោបល់ក្នុងការការពារក្តីរបស់គាត់។[6] លោក **អៀង សារី** ដែលត្រូវបានបញ្ជូនទៅមន្ទីរពេទ្យនៅ ខែ កញ្ញា កាលពីឆ្នាំមុន[7] បានដាក់នូវសំណើរក្នុងការលះបង់សិទ្ធិមានវត្តមានរបស់គាត់ ហើយគាត់បានដកហូតសំណើនេះវិញនៅថ្ងៃទី ៣ ធ្នូ ២០១២។[8] នាពេលនោះ គាត់បានបញ្ជាក់ថា គាត់មាន *"បំណងនឹងចូលរួមដោយផ្ទាល់នៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងបន្ទប់សវនាការដោយមានវត្តមានដោយផ្ទាល់ នៅក្នុងបន្ទប់សវនាការ ជាពិសេស នៅក្នុងអំឡុងពេលស្តាប់សក្ខីកម្មសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី។"[9]*

យ៉ាងណាក្តី នៅថ្ងៃទី ៤ ធ្នូ ២០១២ គ្រូពេទ្យប្រចាំតុលាការម្នាក់ បានរាយការណ៍ថា ស្ថានភាពសុខភាពផ្លូវកាយរបស់ លោក **អៀង សារី** មានសភាព *"មិនល្អ"* ហើយផ្តល់យោបល់ឲជនជាប់ចោទបន្តតាមដានកិច្ចដំណើរការនីតិវិធីនៅបន្ទប់ឃុំឃាំងជាន់ក្រោម។ ដោយហេតុនេះ អង្គជំនុំជម្រះ បានបង្គាប់ឲ លោក **អៀង សារី** ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតាមប្រព័ន្ធសោតទស្សន៍ពីបន្ទប់តាមដានជាន់ក្រោមសាលសវនាការ។[10] ចាប់តាំងពីពេលនោះរហូតមកដល់សប្តាហ៍នេះ លោក **អៀង សារី** បានតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំឃាំងជាន់ក្រោមសាលសវនាការ។ អង្គជំនុំជម្រះ បានបដិសេធសំណើឲថតវីដេអូរ ឬខ្សែអាត់ ពេលជនជាប់ចោទនៅក្នុងបន្ទប់ឃុំឃាំងខាងក្រោមបន្ទប់សវនាការ[11] ប៉ុន្តែ បានអនុញ្ញាតឲអ្នកគ្រប់គ្រងសំណុំរឿងរបស់ក្រុមការពារក្តីចូលទៅក្នុងបន្ទប់នេះ ដើម្បីធ្វើកំណត់ត្រាពាក់ព័ន្ធនឹងស្ថានភាពសុខភាពរបស់ លោក **អៀង សារី**។[12]

អង្គជំនុំជម្រះតុលាការដំបូង បានបញ្ជាក់នៅក្នុងអនុស្សរណៈមួយក្នុងសប្តាហ៍នេះថា បច្ចុប្បន្ននេះ អង្គជំនុំជម្រះ បានកំពុងព្យាយាមស្វែងរកវិធានការដើម្បីកំណត់កាលបរិច្ឆេទនៃការវាយតម្លៃតាមវេជ្ជសាស្ត្រសារឡើងវិញនៃកាយសម្បាល្អរបស់ជនជាប់ចោទ **អៀង សារី** និង **នួន ជា** ដោយអ្នកជំនាញវេជ្ជសាស្ត្រចាត់តាំងដោយតុលាការសម្រាប់ដើមខែមីនា ២០១៣។[13]

## III. ការគ្រប់គ្រងសវនាការ

ដោយសារតែ លោក នួន ជា បានកំពុងសម្រាកនៅមន្ទីរពេទ្យ អង្គជំនុំជម្រះតុលាការដំបូង បានផ្អាកកិច្ចដំណើរការនីតិវិធីនៅថ្ងៃច័ន្ទ។ មិនមានសវនាការទេនៅថ្ងៃបន្ទាប់ក្នុងសប្តាហ៍នេះ ក្រោយពីលោក នួន ជា បានបញ្ជាក់ថា គាត់មិនមានបំណងបោះបង់សិទ្ធិមានវត្តមានក្នុងកិច្ចដំណើរសវនាការទេ ហើយលោក ខៀវ សំផន ក៏ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យផងដែរ។

## ក. វត្តមាន

នៅថ្ងៃច័ន្ទ លោក អៀង សារី បានតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំឃាំងខាងក្រោមបន្ទប់សវនាការ រីឯ លោក ខៀវ សំផន បានមានវត្តមាននៅក្នុងបន្ទប់សវនាការ។ លោក នួន ជា បានអវត្តមានព្រោះគាត់ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដោយសារបញ្ហាសុខភាព។

**វត្តមានចៅក្រម៖** ចៅក្រមជាតិ យូរ ឧត្តរា បានអវត្តមានពីបន្ទប់សវនាការដោយសារហេតុផលផ្ទាល់ខ្លួន។ លោកចៅក្រមត្រូវបានជំនួសដោយចៅក្រមបម្រុង ធូ មណី។[14]

**វត្តមានដើមបណ្តឹងរដ្ឋប្បវេណី៖** មានដើមបណ្តឹងរដ្ឋប្បវេណីប្រហែលជា ១៥ នាក់ បានចូលរួមស្តាប់កិច្ចដំណើរការនីតិវិធីពីបន្ទប់សវនាការនិងសាលសវនាការ។

**វត្តមានភាគី៖** ភាគីទាំងអស់ត្រូវបានតំណាងឲត្រឹមត្រូវនៅថ្ងៃច័ន្ទ ទោះបីជាក្រឡាបញ្ជីបានប្រកាសថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោក ពេជ អង្គ នឹងមកយឺតប្រហែលជាមួយម៉ោង។

**វត្តមានសាធារណជន៖**

| កាលបរិច្ឆេទ | សវនាការពេលព្រឹក | សវនាការពេលរសៀល |
|---|---|---|
| ថ្ងៃច័ន្ទ ១៤/០១/១៣ | ▪ សិស្សានុសិស្ស ១០០នាក់ មកពីអង្គការ ពួរ អង់ សួរៀ ដង់ហ្វង់ (Pour un Surire d'Enfant)<br>▪ អ្នកភូមិ ១០០នាក់ មកពីស្រុក កំពង់ឆ្នាំង និង រលាផ្អើរ ខេត្តកំពង់ឆ្នាំង<br>▪ អ្នកសង្កេតការបរទេស ៣ នាក់ | (*មិនមានសវនាការ*) |

## ខ. ការគ្រប់គ្រងពេលវេលា

ដោយសារតែការសម្រាកព្យាបាលនៅមន្ទីរពេទ្យរបស់ លោក នួន ជា និង លោក ខៀវ សំផន សវនាការលើកស្តុតាងក្នុងសប្តាហ៍នេះ ត្រូវបានលុបចោល។ អង្គជំនុំជម្រះតុលាការដំបូង បានបញ្ជាក់ថា អង្គជំនុំជម្រះ នឹងបើកសវនាការលើឯកសារនេសសប្តាហ៍ក្រោយ។

## គ. តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្តើម | សម្រាក ពេលព្រឹក | អាហារថ្ងៃត្រង់ | សម្រាក ពេលរសៀល | ផ្អាក សវនាការ | រយៈពេល សវនាការសរុប |
|---|---|---|---|---|---|---|
| ថ្ងៃច័ន្ទ ១៤/០១/១៣ | ៩:០៩ | ៩:២៩ | - | - | - | ២០នាទី |
| រយៈពេលសវនាការជាមធ្យម | | | | | ២០ នាទី | |
| រយៈពេលសវនាការសរុបក្នុងសប្តាហ៍នេះ | | | | | ២០ នាទី | |
| ចំនួនម៉ោង ថ្ងៃ និង សប្តាហ៍នៃសវនាការ | | | | | ៦៣៣ ម៉ោង និង ៤២ នាទី | |
| **រយៈពេលសវនាការចំនួន ១៤៤ ថ្ងៃ អំឡុងពេល ៤៥ សប្តាហ៍** | | | | | | |

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings;
- the figures in the *Public Attendance* section of the report are only approximations; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

[*] AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia.

This issue of **KRT TRIAL MONITOR** was authored by Faith Suzzette Delos Reyes, Noyel Ry, and Penelope Van Tuyl, as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT TRIAL MONITOR reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

[1] Trial Chamber. "Adjournment of proceedings" (16 January 2013). E258. 1.

[2] Ibid. *See also* Nuon Chea Defense. "Letter of Non-Waiver Right for NUON Chea" (14 January 2012). E257.

[3] Ibid.

[4] Ibid.

[5] Trial Chamber. "Revised Schedule for Forthcoming Document Hearings (commencing Monday 21 January 2013)" (17 January 2013). E223/3 [hereinafter **REVISED SCHEDULE FOR DOCUMENT HEARINGS**]. Par 2.

[6] CASE 002 KRT TRIAL MONITOR. Issue No. 45, Hearing on Evidence Week 40 (4-7 December 2012). 13-15.

[7] *See* CASE 002 KRT TRIAL MONITOR. Issue No. 36, Hearing on Evidence Week 31 (20-21 September 2012). 3-4.

[8] The Defence for Ieng Sary. "Ieng Sary's Withdrawal of Waivers of Right to be Present" (3 December 2012). E237/2. The waivers bear document numbers E229, E237 and E23711.

[9] Ibid.

[10] Trial Chamber. "Decision on the IENG Sary Defense Request to Audio and/or Video Record IENG Sary in the Holding Cell" (16 January 2013). E254/3.

[11] Ibid, par. 17.

[12] Ibid, par. 11: "…the Chamber notes that on 4 December 2012, it specifically instructed the Defense not to video-record the Accused in the holding cell. The Defense then informed the Chamber that its Case Manager would remain with the Accused in the holding cell in order to take notes. In fact, the Case Manager made a number of audio recordings over the course of two days, including conversations with the Accused's treating physicians without their clear consent, and without filing an appropriate request to the Chamber. The Chamber considers the Defense's approach to this matter verges on misconduct pursuant to Internal Rule 38 and should not be repeated."

[13] REVISED SCHEDULE FOR DOCUMENT HEARINGS. Par. 8.

[14] IR 79 (4) states: "In case of absence of a sitting Judge, the President of the Chamber may, after consultation with the remaining judges, decide to adjourn the proceedings or designate a Reserve Judge to sit in place of the absent Judge for the remainder of the proceedings in question."